# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
*********

# កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ កូម៉ូ អឹភែរឹល ឯ.ក ជាមួយ
## តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ
## ស្តីពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០នាទីព្រឹក នៅក្នុងរោងចក្រ កូម៉ូ អឹភែរឹល ឯ.ក មានកិច្ចប្រជុំមួយរវាងតំណាងរោងចក្រ នឹងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយករោងចក្របានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្នរោងចក្រខ្វះការបញ្ជាទិញ ដែលបណ្តាលឱ្យប្រវាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះរោងចក្រសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៣នាក់ (ស្រី ៧នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ៩៧៨នាក់ (ស្រី ៧៧០នាក់) រយៈពេល ១៤ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣។ ក្នុងអំឡុងពេលព្យួរការងារនេះ កម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ឧបត្ថម្ភ ចំនួន ១៥ដុល្លា។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងានេះ និងបើកជូនបងប្អូនកម្មករ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ ចំនួន ១៥ដុល្លា។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១១:៣០នាទី ព្រឹកនាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និត ស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោបល់សហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ ៧កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣

**នាយករោងចក្រ**

**ស្នាមមេដៃតំណាងកម្មករ និយោជិក និងតំណាងសហជីព**